ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករគណនេយ្យនិងសវនកម្ម
លេខ ០១៧/២៤ ន. គ. ស/ស.ន.ល.

ថ្ងៃព្រហ. ៥កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសក្រុមហ៊ុន ឬវិទ្យាស្ថានវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម លើការបណ្តុះបណ្តាលជំនាញការត្រួតពិនិត្យគុណភាពសវនកម្ម

**និយ័តករគណនេយ្យនិងសវនកម្ម** (ន.គ.ស) គឺជាស្ថាប័ននិយ័តករគណនេយ្យនិងសវនកម្មតែមួយគត់នៅកម្ពុជាដែលជាសេនាធិការឱ្យអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារលើការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យ និងសវនកម្មប្រកបដោយការជឿទុកចិត្តពីស្ថាប័នសាធារណៈ ស្ថាប័នឯកជន គណនេយ្យករ សវនករ និងសាធារណជន។ ដើម្បីអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន **ន.គ.ស** បានដាក់ចេញនូវផែនការអភិវឌ្ឍន៍ស្ថាប័នរយៈពេល ៥ឆ្នាំ (២០២១ - ២០២៥)។ ការអភិវឌ្ឍន៍សមត្ថភាពមន្ត្រីគឺជាសកម្មភាពមួយនៃផែនការអភិវឌ្ឍន៍ស្ថាប័ន។ ក្នុងន័យនេះ **ន.គ.ស.** ត្រូវការជ្រើសរើសក្រុមហ៊ុន ឬវិទ្យាស្ថានវិជ្ជាជីវៈ គណនេយ្យ និងសវនកម្ម ដើម្បីផ្តល់សេវាលើការបណ្តុះបណ្តាល។ ការបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើការកសាងសមត្ថភាពមន្ត្រី **ន.គ.ស.** ទាំងចំណេះដឹង និងការអនុវត្តលើជំនាញការត្រួតពិនិត្យគុណភាពសវនកម្ម និងជំនាញផ្សេងៗទៀត។

ក្នុងន័យនេះ **ន.គ.ស** សូមប្រកាសជ្រើសរើសក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលមានគុណវុឌ្ឍិដូចខាងក្រោម÷

### ១. លក្ខខណ្ឌគុណវុឌ្ឍិ

ក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលអាចចូលរួមក្នុងការដេញថ្លៃបាន លុះត្រាតែជាក្រុមហ៊ុនដែល÷

- ➢ បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និងនៅអគ្គនាយកដ្ឋានពន្ធដារ ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- ➢ បានអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មពេញលេញ
- ➢ មានបទពិសោធន៍បណ្តុះបណ្តាលពាក់ព័ន្ធនឹងការងារសវនកម្មរយៈពេលយ៉ាងតិច ៥ឆ្នាំ
- ➢ មានចំណេះដឹង និងបទពិសោធន៍ការអនុវត្តលើ IFRS Audit Quality (ISQM1 / ISQM2)
- ➢ ធ្លាប់បានចូលរួមក្នុងកិច្ចអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា ត្រូវបានលើកទឹកចិត្ត។

### ២. លក្ខខណ្ឌយោងការងារ

- ➢ ត្រូវផ្តល់នូវការបណ្តុះបណ្តាលពាក់ព័ន្ធនឹង IFRS Audit Quality (ISQM1 / ISQM2)
- ➢ ត្រូវផ្តល់នូវការបណ្តុះបណ្តាលលើនីតិវិធីនៃការរៀបចំសៀវភៅណែនាំស្តីពីការងារសវនកម្ម
- ➢ ត្រូវផ្តល់នូវការបណ្តុះបណ្តាលលើនីតិវិធីលម្អិតលើការចុះត្រួតពិនិត្យគុណភាពសវនកម្មលើក្រុមហ៊ុនសវនកម្ម
- ➢ ត្រូវផ្តល់នូវការចុះអនុវត្តជាក់ស្តែងលើការចុះត្រួតពិនិត្យគុណភាពសវនកម្ម។

## ៣. សមិទ្ធផលដែលត្រូវផ្តល់

ក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលទទួលជោគជ័យក្នុងការដេញថ្លៃ ត្រូវផ្តល់ជូន **ន.គ.ស** នូវការវិភាគលម្អិត និងស៊ីជម្រៅអំពីការអនុវត្តកាតព្វកិច្ចរួមមានដូចជា÷

- មន្ត្រីជំនាញអាចស្វែងយល់ស៊ីជម្រៅលើមូលដ្ឋានគ្រឹះអំពីការប្រព្រឹត្តទៅនៃការធ្វើសវនកម្មហិរញ្ញវត្ថុ
- មន្ត្រីជំនាញអាចស្វែងយល់ស៊ីជម្រៅស្តង់ដាស្តីពីការគ្រប់គ្រងគុណភាពសវនកម្មអន្តរជាតិ (ISQM1 & ISQM2)
- មន្ត្រីជំនាញអាចយល់ដឹងកាន់តែស៊ីជម្រៅអំពីនីតិវិធីនៃការចងក្រងសៀវភៅណែនាំស្តីពីការធានាសវនកម្ម (Quality Assurance Manual)
- មន្ត្រីជំនាញសិក្សាពីដំណើរការប្រព្រឹត្តទៅនៃការចុះត្រួតពិនិត្យគុណភាពសវនកម្មលើក្រុមហ៊ុនសវនកម្ម និងនីតិវិធី នៃការរៀបចំរបាយការណ៍បិទបញ្ចប់ការចុះត្រួតពិនិត្យគុណភាពសវនកម្ម
- មន្ត្រីជំនាញអាចអនុវត្តជាក់ស្តែងទៅលើការធ្វើសវនកម្មហិរញ្ញវត្ថុ
- មន្ត្រីជំនាញអាចអភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួនឱ្យកាន់តែប្រសើរឡើងដើម្បីឈានទៅរកការក្លាយជាអ្នកត្រួតពិនិត្យ ឯករាជ្យនាពេលអនាគត។

## ៤. កម្រៃ

កម្រៃសម្រាប់ការបណ្តុះបណ្តាល គឺបើកចំហរសម្រាប់ការចរចា។

## ៥. រយៈពេលសម្រាប់ការបណ្តុះបណ្តាល

ការបណ្តុះបណ្តាលខាងលើនេះមានរយៈពេលមិនលើស១ (មួយ) ខែ។ ក្នុងករណីមានការបន្ត ឬពន្យារពេលក្នុងការបណ្តុះបណ្តាលលើស ១ (មួយ) ខែ នឹងត្រូវមានការពិភាក្សា និងចរចា។ កិច្ចសន្យានៃការផ្តល់សេវាបណ្តុះបណ្តាល នឹងត្រូវបង្កើតឡើងរវាង **ន.គ.ស** ជាមួយនឹងក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលបានទទួលជោគជ័យក្នុងការដេញថ្លៃ។

## ៦. ការដាក់ពាក្យ

ក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលមានចំណាប់អារម្មណ៍ សូមផ្ញើសេចក្តីចំណាប់អារម្មណ៍មក **ន.គ.ស** តាមរយៈអ៊ីម៉ែល t.satya@acar.gov.kh និង h.sokunthea@acar.gov.kh ត្រឹមថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ ដោយដាក់ទាំងសំណើបច្ចេកទេស (Technical Proposal) និងសំណើហិរញ្ញវត្ថុ (Financial Proposal)។

សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមទាក់ទងតាមអាសយដ្ឋាន ឬលេខទូរស័ព្ទ ដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគារ “ក” ជាន់ទី១ ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរស័ព្ទទាក់ទង និងតេឡេក្រាម ÷ ០៦៩៧៨៣៩៣៦ / ០១២ ៧៩៣ ៣៩៨

**និយ័តករគណនេយ្យនិងសវនកម្ម**